## រចនាសម្ព័ន្ធចាត់តាំង
## វិទ្យាស្ថានយោធាកម្ពុជា




## អនុក្រឹត្យលេខ ១៧ អនក្រ.បក
## ស្តីពីការ
## បង្កើតសង្កាត់កោះរ៉ុង ចំណុះខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
~~~

តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-**

ត្រូវបានបង្កើតសង្កាត់កោះរ៉ុង ចំណុះខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដោយកាត់យកភូមិសាស្ត្រមួយចំនួនរបស់សង្កាត់លេខ ៣ ក្នុងខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា ២ .-**

សង្កាត់កោះរ៉ុង មានព្រំប្រទល់រដ្ឋបាល :

- ខាងជើង ទល់នឹងសមុទ្រ ស្រុកបូទុមសាគរ ខេត្តកោះកុង
- ខាងកើត ទល់នឹងសមុទ្រ សង្កាត់លេខ ៣ ខ័ណ្ឌមិត្តភាព
- ខាងលិច ទល់នឹងសមុទ្រ ស្រុកគិរីសាគរ ខេត្តកោះកុង
- ខាងត្បូង ទល់នឹងសមុទ្រ

**មាត្រា ៣ .-**

ទីតាំងរដ្ឋបាលសង្កាត់កោះរ៉ុង ស្ថិតនៅក្នុងភូមិដើមថ្កូវ ។

**មាត្រា ៤ .-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**